# លទ្ធផលសង្ខេបវេទិកាពិភាក្សាលើកទី១
# ស្តីពី

# « យុវជននិងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ »

ឧបត្ថម្ភថវិកាដោយ ៖ SPIDER



# « យុវជននិងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៣»

រៀបចំដោយ ៖ សម្ព័ន្ធភាពជាតិ ឃុំ សង្កាត់ និង អង្គការវិទ្យាស្ថានបើកទូលាយ

កាលបរិច្ឆេទ ៖ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២

សមាជិកចូលរួមក្នុងវេទិកា៖ ៤៨ នាក់ (ស្ត្រី ២៤នាក់ បុរស២៤ នាក់) ក្នុងនោះមាន៖

- ១៣នាក់ (ស្ត្រី ៧នាក់ជាយុវនារី) ជាសមាជិកសភាយុវជននៅទីក្រុងភ្នំពេញ និងជាសមាជិកក្លឹបមកពី បណ្តាលខេត្ត កំពង់ឆ្នាំង ក្រចេះ និងកំពង់ស្ពឺ ដែលជា ក្រុមគោលដៅរបស់អង្គការយុវជនខ្មែរ និងការ អភិវឌ្ឍន៍
- ១៣នាក់(ស្ត្រី៧នាក់) ជាយុវជនមកពីសមាជិកបណ្តាញមិត្តអប់រំមិត្តរបស់សមាគមសុខភាពប្រជាជន
- ៦ នាក់ (ស្ត្រី ៣នាក់)ជាក្រុមប្រឹក្សាឃុំ សង្កាត់ អញ្ជើញមកពីខេត្តសៀមរាបចំនួន២នាក់ ខេត្តបាត់ដំបង ចំនួន២នាក់ និងខេត្តកណ្តាលចំនួន២នាក់
- ១២នាក់(៦នាក់ជាស្ត្រី)ជាបុគ្គលិកមកពី VOD, YCC, NICFEC, KYA, PHD, COMFREL, YRDP, KYSD, OI ។
- ៤នាក់(ស្ត្រី ១នាក់)ជាមន្ត្រីរដ្ឋាភិបាលអញ្ជើញមកពីក្រសួងកិច្ចការនារី និងគណៈកម្មការជាតិរៀបចំការ បោះឆ្នោត

# គោលបំណងនៃវេទិកាពិភាក្សា

គោលបំណងទូទៅនៃអង្គវេទិកាពិភាក្សាគឺផ្តល់នូវឱកាសសម្រាប់យុវជននិងក្រុមប្រឹក្សាឃុំសង្កាត់ធ្វើការពិភាក្សាអំពីកម្រិតនៃការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោតថ្នាក់ជាតិនាឆ្នាំ ២០១៣។

គោលបំណងជាក់លាក់នៃវេទិកា៖

- ផ្តល់ឱកាសដល់យុវជន មន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងអង្គការសង្គមស៊ីវិលដែលធ្វើការជាមួយក្រុមយុវជននិងការបោះឆ្នោតចែករំលែកទស្សនៈនិងការសង្កេតរបស់ខ្លួនចំពោះការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោត។
- កំណត់យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣នឹងការបោះឆ្នោតជាបន្តបន្ទាប់ទៅមុខទៀត។

មានបទបង្ហាញចំនួន៣៖

- «នីតិវិធី និងដំណើរការនៃការបោះឆ្នោតជាតិឆ្នាំ២០១៣ » ដោយតំណាងគណៈធម្មាធិការជាតិរៀបចំការបោះឆ្នោត
- «តួនាទីសំខាន់របស់យុវជនក្នុងការបោះឆ្នោត ឧបសគ្គ និងឱកាស»  ដោយតំណាង យុវជនរបស់សភាយុវជន
- «ទស្សនាទានទូទៅចំពោះការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត»ដោយ តំនាងអង្គការខុមប្រែល

# សំណួរពិភាក្សា



១-តើព័ត៌មានស្តីពីការបោះឆ្នោតប្រភេទណាខ្លះដែលយុវជនគួរនិងត្រូវដឹង?
២-ហេតុអ្វីយុវជនគឺជាអ្នកសំខាន់ក្នុងដំណើរការបោះឆ្នោត?
៣-តើប្រជាពលរដ្ឋជាពិសេសយុវជនអាចទទួលព័ត៌មានអំពីការបោះឆ្នោតនៅឯណា?ហើយតាមវិធីណាដែរ?
៤-តើឧបសគ្គអ្វីខ្លះដែលរារាំងដល់ការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោត?
៥-តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត?

# លទ្ធផលពិភាក្សា

## តើព័ត៌មានស្តីពីការបោះឆ្នោតប្រភេទណាខ្លះដែលយុវជនគួរនិងត្រូវដឹង?



គ្រប់ព័ត៌មានស្តីពីការបោះឆ្នោត ដូចជា

- ថ្ងៃបោះឆ្នោត
- កន្លែង
- និងរបៀបការចុះឈ្មោះ
- អត្តសញ្ញាណប័ណ្ណដែលត្រូវប្រើសម្រាប់បោះឆ្នោត
- ព័ត៌មានស្តីពីគោលនយោបាយរបស់គណៈបក្សនីមួយៗដែលអាចជួយពួកគាត់ធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការជ្រើសរើសគណៈបក្សណាមួយក្នុងថ្ងៃបោះឆ្នោត

# លទ្ធផលពិភាក្សា

## ហេតុអ្វីយុវជនគឺជាអ្នកសំខាន់ក្នុងដំណើរការបោះឆ្នោត?

ក-យុវជនដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការបោះឆ្នោតពីព្រោះតួលេខរបស់យុវជននាពេលបច្ចុប្បន្ននេះអាចផ្លាស់ប្តូរអនាគតរបស់ប្រទេសជាតិបាន

ខ-យុវជនគឺជាក្មេងជំនាន់ក្រោយដែលមានការសិក្សាខ្ពស់ មានសុខភាពល្អ និងបាមពលខ្លាំងជាងមនុស្សចាស់ ដូច្នេះការសម្រេចចិត្តរបស់ពួកគេអាចជះឥទ្ធិពលដល់មេដឹកនាំកំពូលៗ និងមានអនុភាពលើការអភិវឌ្ឍគោលនយោបាយនានាបាន

គ-យុវជនគឺជាគន្លឹះក្នុងការផ្សព្វផ្សាយនៃលំហូរព័ត៌មានស្តីពីការបោះឆ្នោត និងដើរតួជាជនគំរូក្នុងការចូលរួមក្នុងបរិយាកាសនយោបាយ

ឃ-ទោះបីជាយ៉ាងនេះក្តី យុវជននៅតែត្រូវការការលើកទឹកចិត្ត និងការណែនាំពីគ្រួសារ មិត្តភក្តិ និងមនុស្សចាស់ក្នុងរឿងបោះឆ្នោត

ង-ស្នើដោយក្រុមប្រឹក្សា ជា ការប្រសើរប្រសិនបើយុវជនស្ម័គ្រចិត្តក្នុងការធ្វើការងារជាមួយបុគ្គលិករបស់ឃុំ និងមេភូមិក្នុងការចែកប័ណ្ណព័ត៌មានដែលចេញដោយគ.ជ.ប ។

# លទ្ធផលពិភាក្សា

## តើប្រជាពលរដ្ឋជាពិសេសយុវជនអាចទទួលព័ត៌មានអំពីការបោះឆ្នោតនៅឯណា? ហើយតាមវិធីណាដែរ?

ក-អាជ្ញាធរមូលដ្ឋាន(ការិយាល័យឃុំ) NEC, PEC, SEC, បណ្តាញសារព័ត៌មានដែលរួមមានកាសែត វិទ្យុ ទូរទស្សន៍ជាមណ្ឌលមួយដែលគេអាចស្វែងរកព័ត៌មានស្តីពីការបោះឆ្នោត

ខ-យុវជនអាចទទួលបានព័ត៌មានដោយក្តារព័ត៌មានរបស់ឃុំ និងអាចទាក់ទងជាមួយមន្ត្រីរបស់ឃុំ ស្មៀនដើម្បីបញ្ជាក់អំពីព័ត៌មានបោះឆ្នោតឬចូលទៅកាន់គេហទំព័ររបស់គ.ជ.ប

គ-ក្រុមប្រឹក្សាឃុំ បានប្រជុំជាមួយអ្នកភូមិដើម្បីផ្សព្វផ្សាយនិងផ្តល់ចំណេះដឹងអំពីរឿងបោះឆ្នោត

ឃ-ព័ត៌មានបោះឆ្នោតគួររៀបចំឲ្យមានលក្ខណៈងាយស្រួលដែលអាចឲ្យជនពិការ និងអ្នកមិនចេះអក្សរអាចយល់ដឹងពីព័ត៌មានទាំងនោះបាន។

# លទ្ធផលពិភាក្សា

## តើឧបសគ្គអ្វីខ្លះដែលរាំងដល់ការចូលរួមរបស់យុវជនក្នុងដំណើរការបោះឆ្នោត?

ក-ដោយស្ថានភាពជីវភាព ជា ពិសេសយុវជនត្រូវធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ នៅ ប្រទេសថៃ ម៉ាឡេស៊ី កូរ៉េ ដែលគេមិនអាចចូលរួមក្នុងដំណើរបោះឆ្នោត ឬខកខានមិនបានទៅបោះឆ្នោត។

ខ-ព័ត៌មានបោះឆ្នោតមិនបានចែកចាយទូទាំងប្រទេស

គ-យុវជនមិនសូមមានចំណាប់អារម្មណ៍ក្នុងស្វែងរក ឬយល់ដឹងអំពីព័ត៌មានបោះឆ្នោត ។លើសពីនេះទៀតគេមិនឲ្យតម្លៃរបស់សន្លឹកឆ្នោតពីព្រោះពួកគេមិនជឿជាក់លើគណ:បក្សណាមួយក្នុងការដោះស្រាយបញ្ហាជីវភាពរបស់ពួកគេ

ឃ-ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោតមិនត្រូវបានឲ្យតម្លៃ ហើយគ្រួសាររបស់គេបានរាំងកូនៗរបស់ពួកគេពីការពាក់ព័ន្ធជាមួយនិងនយោបាយពីព្រោះការភ័យខ្លាចចំពោះការចាប់ខ្លួននិងជាប់គុកយោងតាមបទពិសោធន៍របស់សង្គម

# លទ្ធផលពិភាក្សា

## តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត?

ក- គ.ជ.ប គួរតែផ្តល់ថវិកា ទៅ កាន់ គណៈកម្មការបោះឆ្នោតថ្នាក់ខេត្ត (Provincial Election Committee-PEC) និង គណៈកម្មការបោះឆ្នោតថ្នាក់សង្កាត់ ( Sangkat Election Committee-SEC) ដើម្បីរៀបចំការប្រជុំ ចែកចាយព័ត៌មានបោះឆ្នោតជាមួយសហគមន៍មូលដ្ឋានដែលយុវជនរស់នៅ

ខ-វាជាការប្រសើរប្រសិនបើនីតិវិធីនៃការចុះឈ្មោះ និងការបោះឆ្នោតមានលក្ខណៈងាយស្រួលពីព្រោះវាអាចជួយលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការចុះឈ្មោះ ។

គ-យន្តការត្រួតពិនិត្យគឺត្រូវមានដើម្បីកត់ត្រារាល់សមិទ្ធផល និងឧបសគ្គនៃអ្នកឈ្នះឆ្នោតដើម្បីប្រៀបធៀបទៅនឹងអ្វីដែលគេបានសន្យាក្នុងគោលនយោបាយក្នុងអាណត្តរបស់ខ្លួន។

# លទ្ធផលពិភាក្សា

## តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការបោះឆ្នោត?

ឃ-ប្រើប្រាស់វិធីសាស្ត្របែបវិជ្ជមានដែលបង្ហាញពីផលប្រយោជន៍នៃការបោះឆ្នោត ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជន

ង-គ.ជ.បគួរតែកែទម្រង់រដ្ឋបាលរបស់ខ្លួនបន្ថិចជាពិសេសការគ្រប់គ្រងបញ្ជីឈ្មោះ ដែលមិនមានឈ្មោះក្នុងថ្ងៃបោះឆ្នោត

ច-ដើម្បីជៀសវាងចំណាកស្រុកដែលវាជះឥទ្ធិពលដល់ការបោះឆ្នោត រដ្ឋាភិបាលគួរតែបង្កើនការងារនៅក្នុងស្រុកឲ្យបានច្រើន។

ឆ-ការផលិតព័ត៌មានរបស់ គ.ជ.បមានលក្ខណៈមិនគួរឲ្យចាប់អារម្មណ៍ដែលធ្វើឲ្យទស្សនិកជនប្តូរប៉ុស្តិ៍ជានិច្ច ។សូមស្នើឲ្យការផលិតមានចំណុចគួរឲ្យចាប់អារម្មណ៍។

សូមអរគុណ!